00868512

002/19-09-2007-ECCC/TC
E1/140

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12 / 12 / 2012
ម៉ោង (Time/Heure): 09 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ច័ន្ទ ទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្ដី- ថ្ងៃទី ១២៧

រៀបចំដោយ: ឌុច ផារី និង Matteo CRIPPA

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរ |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោក Matteo CRIPPA, លោក ដាវ អានសាន |
| ការិយាល័យសហព្រះរាជអាជ្ញា៖ កញ្ញា សុង ឆវ័ន្ត, លោក Dale LYSAK |
| ជនជាប់ចោទ៖ នួន ជា, ខៀវ សំផន (អៀង សារី អវត្តមានដោយមូលហេតុសុខភាព) |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Jasper PAUW |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT, លោក ពេជ អង្គ, លោកស្រី ទី ស្រីនណា, លោក ហុង គីមសួន, លោក វ៉ែន ពៅ, លោក សំ សុគង់, លោក Pascal AUBOIN, លោកស្រី Christine MARTINEAU, លោកស្រី Nushin SAKARATI, លោកស្រី Beini YE |
| សាក្សី/ដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ស៊ុំ ជា ហៅ ជា (TCW-690) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ លោក លឹម ប៊ុនហេង (មេធាវីប្រឹក្សារបស់សាក្សី) លោក Jay GALIK |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៦.១០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១១.០០ | បញ្ចប់ម៉ោង៖ ១១.២០ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.១៥ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកពេលល្ងាច | ចាប់ផ្តើមម៉ោង៖ ១៤.៥០ | បញ្ចប់ម៉ោង៖ ១៣.១០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៥ ម៉ោង និង ១០ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | អង្គជំនុំជម្រះ | ៩.០៣ | ០៩.០៤ |
| | មេធាវីការពារក្តី នួន ជា | ១២.១៣ | ១២.១៤ |
| ការតាំងសំណួរទៅសាក្សី ស៊ុំ ជា ហៅ ជា (TCW-690) | អង្គជំនុំជម្រះ | ០៩.០៦ | ០៩.១៤ |
| | សហព្រះរាជអាជ្ញា | ០៩.១៤ | ១១.២៨ |
| | មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ១១.៣៣ | ១២.១៣ |
| | អង្គជំនុំជម្រះ | ១៣.៣៥ | ១៣.៥៦ |
| | មេធាវីការពារក្តី នួន ជា | ១៣.៥៧ | ១៥.៥១ |
| | មេធាវីការពារក្តី អៀង សារី | ១៥.៥១ | ១៦.១០ |
| សេចក្តីសម្រេចផ្ទាល់មាត់អំពីការប្រើប្រាស់ | អង្គជំនុំជម្រះ | ១០.៤៧ | ១០.៥៤ |

| | | | |
|---|---|---|---|
| នូវសេចក្តីថ្លែងការណ៍របស់សាក្សីដែលមិនមានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះ | | ១៥.២៥ | ១៥.២៨ |
| សេចក្តីសម្រេចផ្ទាល់មាត់អំពីការកំណត់ពេលវេលាសម្រាប់ប្រើប្រាស់នូវបញ្ជីឈ្មោះអ្នកទោស ស-២១ | អង្គជំនុំជម្រះ | ១១.៣០ | ១១.៣៣ |
| សេចក្តីសម្រេចអំពីការប្រើប្រាស់ឯកសារនៅពេលតាំងសំណួរដល់សាក្សី | អង្គជំនុំជម្រះ | ១៤.៣៦ | ១៤.៤០ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

ជនជាប់ចោទ អៀង សារី បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់សម្រាប់រយៈពេលពេញមួយថ្ងៃ ក្នុងអំឡុងពេលនៃការស្តាប់សក្ខីកម្មរបស់សាក្សី ស៊ុំ ជា ហៅ ជា (TCW-690) ។

ជនជាប់ចោទ នួន ជា តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការសម្រាប់ពេលរសៀល។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមការស្នើសុំរបស់ជនជាប់ចោទទាំងពីរ។

**ការតាំងសំណួរទៅសាក្សី ស៊ុំ ជា ហៅ ជា (TCW-690)**

អង្គជំនុំជម្រះតាំងសំណួរបឋមមួយចំនួនដល់សាក្សី បន្ទាប់មកការតាំងសំណួរបន្តដោយសហព្រះរាជអាជ្ញា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះ (ចៅក្រម Lavergne) និងមេធាវីការពារក្តី នួន ជា មេធាវីការពារក្តី អៀង សារី ។ មេធាវីការពារក្តី ខៀវ សំផន មិនមានសំណួរនោះទេ។

**សេចក្តីសម្រេចផ្ទាល់មាត់អំពីការប្រើប្រាស់នូវសេចក្តីថ្លែងការណ៍របស់សាក្សីដែលមិនមានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះ**

អង្គជំនុំជម្រះបានរំឭកឡើងវិញនូវសេចក្តីសម្រេចរបស់ខ្លួនដែលបានប្រកាសពីពេលមុន ដែលក្នុងសេចក្តីសម្រេចនោះអង្គជំនុំជម្រះបានសម្រេចថា "ភាគីមិនអាចដកស្រង់នូវផ្នែកណាមួយនៃកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីផ្សេង យកមកធ្វើជាមូលដ្ឋានក្នុងការតាំងសំណួរដល់សាក្សីដែលកំពុងតែផ្តល់សក្ខីកម្មនោះទេ។ ភាគីអាចប្រើនូវ

ព័ត៌មានទូទៅដែលមានក្នុងកំណត់ហេតុនោះ ដើម្បីសួរសំណួរទូទៅដល់សាក្សីបាន” ។

**<u>សេចក្តីសម្រេចអំពីការកំណត់ពេលវេលានៃការប្រើប្រាស់នូវបញ្ជីឈ្មោះអ្នកទោស ស-២១</u>**

អង្គជំនុំជម្រះបានសម្រេចថា ដើម្បីជាប្រតិចារឹក ភាគីអាចធ្វើការកត់សម្គាល់នូវឈ្មោះរបស់បុគ្គល ដែលមាននៅក្នុងបញ្ជីឈ្មោះអ្នកទោស ស-២១ ដែលបានកែប្រែ ក្នុងអំឡុងពេលដែលបានប្រគល់ទៅឱ្យភាគីដើម្បីតាំងសំណួរនោះ ។ អង្គជំនុំជម្រះនឹងមិនផ្តល់នូវពេលវេលាផ្សេងទៀតឱ្យទៅភាគីដើម្បីធ្វើដូច្នេះនោះទេ ។

**<u>សេចក្តីសម្រេចអំពីការប្រើប្រាស់ឯកសារនៅពេលតាំងសំណួរដល់សាក្សី</u>**

អង្គជំនុំជម្រះបានសម្រេចថា មេធាវីការពារក្តី នួន ជា អាចប្រើប្រាស់នូវព័ត៌មានជាសារធាតុដែលមាននៅក្នុងសៀវភៅដែលបាននិព័ន្ធដោយ Michael Vickery ដើម្បីសួរសំណួរបាន តែមិនអាចដកស្រង់នូវចំណុចណាមួយជាក់លាក់ក្នុងសៀវភៅនោះ ដើម្បីសួរសំណួរដល់សាក្សីនោះទេ ។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in France |
|---|---|---|---|---|---|---|---|
| E3/3961 | D94/9 | 00205056-00205060<br>00223344-00223348<br>00705375-00705381 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុំ ជា<br>[Corrected 1] Written Record of Interview of SUM Chea<br>[Corrigé 1] Procès verbal d'audition de SUM Chea | P | 00205057-58 | 00223345-47 | 00705376-79 |
| E3/3962 | D166/117 | 00287533-00287541<br>00293362-00293369<br>00355870-00355878 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម សំហួន KHOEM Sâmhuon<br>Written Record of Interview of KHOEM Sâmhuon<br>Procès verbal d'audition de YEAN Lun យាន លន់ | P | 00287535-36 | 00293364-65 | 00355872-73 |
| E3/342 | D288/6.68.1 | 00329596-00330129 | ឧបសម្ព័ន្ធ ១៖ ការពិនិត្យឡើងវិញបញ្ជីអ្នកទោសនៅមន្ទីរស ២១ | P | | | |
| E3/2374 | D108/50/1.2 | 00191136-00191137 | Annex 2: 1:10,000 scale colour map of Phnom Penn, on the reverse is the street guide and locations of buildings in the city | P | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/1757 | D222/1.17 | 00710225-00710230, 00789169-00789258 00396894-00397284 00700095-00700099, 00763550-00763601 | សៀវភៅរៀបរៀងដោយ VICKERY Michael, Cambodia 1975-1982 ប្រទេសកម្ពុជា ឆ្នាំ១៩៧៥-១៩៨២ Book by VICKERY Michael, Cambodia 1975-1982 Book by VICKERY Michael, Cambodia 1975-1982 | P | | 00396998 | |
| E3/1568 | D313/1.2.406.1 | 00713919-00713993 00651862-00651907 00743328-00743384 | អត្ថបទដែលបានវាយសារឡើងវិញពីអត្ថបទសរសេរដោយដៃនៃបទសម្ភាសន៍ជាមួយ ជា ស៊ីម ថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ១៩៩១ និង ហេង សំរិន ២ ខែធ្នូ ឆ្នាំ ១៩៩១ នៅទីក្រុងភ្នំពេញ RETYPED from a Handwritten interview of CHEA Sim, Phnom Penh, 3 Dec 1991, and Heng Samrin, Phnom Penh, 2 Dec 1991 Transcription dactylographique de notes manuscrites prises durant des entretiens menés avec Heng Samrin et Chea Sim à Phnom, les 2 et 3 décembre 1991 respectivement | P | 00713947, 00713945, 00713958 | 00651879, 00651878, 00651886 | 00743351 |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា (១២.១៤) ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការសម្រាប់ពេលរសៀល និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សីនិងអ្នកជំនាញជូនសាក្សី ស៊ុំ ជា TCW-690 ត្រឡប់ទៅលំនៅដ្ឋានរបស់គាត់វិញ និងបង្គាប់ឱ្យនាំដើមបណ្តឹងរដ្ឋប្បវេណី TCCP-89 ត្រឡប់ទៅកន្លែងស្នាក់នៅរបស់គាត់ នឹងបង្គាប់ឱ្យនាំគាត់មកកាន់បន្ទប់សវនាការវិញនៅថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩.០០ ព្រឹក ថ្ងៃអង្គារ ទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

**សវនាការនឹងបន្តនៅថ្ងៃ អង្គារ ទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។**

ភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ឌុច ផារី** Matteo CRIPPA